**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ១៦២.....ណ.ព

**សូមគោរពជូន**

**ឯកឧត្តម សម រង្ស៊ី ប្រធានគណបក្ស សម រង្ស៊ី**

***ឯកឧត្តមប្រធាន***

ខ្ញុំមានកិត្តិយសដ៏ខ្ពង់ខ្ពស់ សូមជម្រាបជូនឯកឧត្តមប្រធានជ្រាបថា នៅក្នុងកម្មវិធីនយោបាយសម្រាប់អាណត្តិថ្មីរបស់ខ្លួន រាជរដ្ឋាភិបាលកម្ពុជាបានប្តេជ្ញាការពារនូវឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដី និងអព្យាក្រឹតភាព នៃព្រះរាជាណាចក្រកម្ពុជា ឱ្យបានស្ថិតស្ថេរគង់វង្ស ។

ដើម្បីអនុវត្តគោលនយោបាយនេះ ប្រកបដោយប្រសិទ្ធភាពនោះ រាជរដ្ឋាភិបាលបានសន្យាថា នឹងស្នើទៅព្រះមហាក្សត្រ ដើម្បីព្រះអង្គទ្រង់ប្រទាននូវព្រះរាជក្រឹត្យ បង្កើតឡើងនូវក្រុមប្រឹក្សាជាតិជាន់ខ្ពស់ទទួលបន្ទុកកិច្ចការព្រំដែន ដែលមានសមាសភាពដូចខាងក្រោម :

-តំណាងព្រះមហាក្សត្រ ០១ រូប ជាប្រធាន

-តំណាងប្រធានព្រឹទ្ធសភា ០១ រូប ជាអនុប្រធាន

-តំណាងប្រធានរដ្ឋសភា ០១ រូប ជាអនុប្រធាន

-តំណាងប្រមុខរាជរដ្ឋាភិបាល ០១ រូប ជាសមាជិក

- តំណាងនៃគណបក្សនយោបាយ ដែលមានអាសនៈនៅក្នុងរដ្ឋសភា ក្នុងមួយគណបក្ស ០១ រូប ជា សមាជិក។

ដោយហេតុដូចបានជម្រាបជូនខាងលើនេះ ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំសូមឯកឧត្តមប្រធានចាត់តំណាង ០១ រូប របស់គណបក្ស សម រង្ស៊ី ដើម្បីចូលរួមធ្វើជាសមាជិកក្រុមប្រឹក្សាជាតិជាន់ខ្ពស់ទទួលបន្ទុកកិច្ចការព្រំដែន តាមការគួរ។

សូមឯកឧត្តមប្រធានទទួលនូវគារវភក្តីអំពីខ្ញុំ។ ៚

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មករា ឆ្នាំ ២០០៥

**ហ៊ុន សែន**

នស/រកត/០៤០៥/១៩៣

# ព្រះរាជក្រឹត្យ

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជ្យរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្សិរីរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/ ០៩ ចុះថ្ងៃ ទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៤៩៦/២៥ ចុះថ្ងៃទី ០៨ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតអាជ្ញាធរជាតិសម្រាប់ទទួលបន្ទុកដោះស្រាយកិច្ចការព្រំដែន

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា១** : ត្រូវបានបង្កើតក្រុមប្រឹក្សាជាតិជាន់ខ្ពស់ទទួលបន្ទុកកិច្ចការព្រំដែន ដើម្បីអនុវត្តកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងការការពារបូរណភាពទឹកដីឱ្យបានស្ថិតស្ថេរគង់វង្ស ស្របតាមមាត្រា២នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា២** : ក្រុមប្រឹក្សាជាតិជាន់ខ្ពស់ទទួលបន្ទុកកិច្ចការព្រំដែន មានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| ១-តំណាងព្រះមហាក្សត្រ | ១រូប | ជាប្រធាន |
| ២-តំណាងប្រធានព្រឹទ្ធសភា | ១រូប | ជាអនុប្រធាន |
| ៣-តំណាងប្រធានរដ្ឋសភា | ១រូប | ជាអនុប្រធាន |
| ៤-តំណាងប្រមុខរាជរដ្ឋាភិបាល | ១រូប | ជាសមាជិក |
| ៥-តំណាងគណបក្សប្រជាជនកម្ពុជា | ១រូប | ជាសមាជិក |
| ៦-តំណាងគណបក្សហ៊្វុនស៊ិនប៉ិច | ១រូប | ជាសមាជិក |
| ៧-តំណាងគណបក្សសមរង្ស៊ី | ១រូប | ជាសមាជិក |

**មាត្រា៣** : ក្រុមប្រឹក្សាជាតិជាន់ខ្ពស់ទទួលបន្ទុកកិច្ចការព្រំដែនមានភារកិច្ច :

-ស្រាវជ្រាវ និងសិក្សាពីបញ្ហាព្រំដែនគោក និងព្រំដែនសមុទ្រ រវាងព្រះរាជាណាចក្រកម្ពុជា ជាមួយបណ្តាប្រទេសជិតខាង

-ជូនយោបល់ដល់រាជរដ្ឋាភិបាល ក្នុងការកសាងលិខិតបទដ្ឋានមានលក្ខណៈច្បាប់ ស្តីពីការកំណត់ព្រំដែនដីគោក និងព្រំដែនសមុទ្រ ក៏ដូចជាការអនុវត្តគោលនយោបាយការពារបូរណភាពទឹកដី របស់រាជរដ្ឋាភិបាល និងតាមដានការវិវត្តលទ្ធផលនៃដំណោះស្រាយព្រំដែន ដែលទទួលបានក្នុងការចរចា ក៏ដូចជាការអនុវត្តលើដីជាក់ស្តែង រវាងព្រះរាជាណាចក្រកម្ពុជាជាមួយបណ្តាប្រទេសជិតខាង

-ចុះពិនិត្យលើដីជាក់ស្តែងនូវព្រឹត្តិការណ៍ ដែលកើតមានឡើងនៅតាមបណ្តោយព្រំដែននៃព្រះរាជាណាចក្រកម្ពុជា ជាមួយបណ្តាប្រទេសជិតខាង

-ធ្វើរបាយការណ៍តាមកំណត់កាលនីមួយៗ ថ្វាយព្រះមហាក្សត្រ អំពីសភាពការណ៍នៃការដោះស្រាយបញ្ហាព្រំដែនរវាងព្រះរាជាណាចក្រកម្ពុជា ជាមួយបណ្តាប្រទេសជិតខាង។

**មាត្រា៤** :ការប្រជុំនៃក្រុមប្រឹក្សាជាតិជាន់ខ្ពស់ទទួលបន្ទុកកិច្ចការព្រំដែន ត្រូវកោះប្រជុំដោយប្រធាន ឬតាមសំណើចំនួនពីរភាគបីយ៉ាងតិចនៃសមាជិកក្រុមប្រឹក្សាជាតិជាន់ខ្ពស់ទទួលបន្ទុកកិច្ចការព្រំដែន។

**មាត្រា៥** :ការប្រជុំ និងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជាតិជាន់ខ្ពស់ទទួលបន្ទុកកិច្ចការព្រំដែន ត្រូវយកតាមការឯកភាពគ្នាលើមតិនៃសមាជិកវត្តមានទាំងអស់ ។ សមាជិកនៃក្រុមប្រឹក្សាជាតិជាន់ខ្ពស់ទទួលបន្ទុកកិច្ចការព្រំដែន ត្រូវរក្សាការសម្ងាត់នៃអង្គប្រជុំ។

**មាត្រា៦** :គណៈកម្មាធិការទទួលបន្ទុកកិច្ចការព្រំដែននៃរាជរដ្ឋាភិបាល ជាលេខាធិការរបស់ក្រុមប្រឹក្សាជាតិជាន់ខ្ពស់ទទួលបន្ទុកកិច្ចការព្រំដែន ។

**មាត្រា៧**: រាល់ការចំណាយសម្រាប់ដំណើរការរបស់ក្រុមប្រឹក្សាជាតិជាន់ខ្ពស់ទទួលបន្ទុកកិច្ចការព្រំដែន ជាបន្ទុករបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

**មាត្រា៨**: នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តនូវព្រះរាជក្រឹត្យនេះ។

**មាត្រា៩**: ព្រះរាជក្រឹត្យនេះមានអានុភាព ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា

នរោត្តម សីហមុនី

នស/រកត.០៥០៤/២០៦

**ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃ ទី ១៧ ខែ មេសា ឆ្នាំ ២០០៥**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
លេខ:០១២/០៥ រ.ចច
រាជធានីភ្នំពេញ ,ថ្ងៃទី២៧ខែមេសាឆ្នាំ២០០៥
សម្តេចចៅហ្វាវាំង វរវៀងជ័យ អធិបតីស្រីង្គារ
ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីព្រះបរមរាជវាំង
ហត្ថលេខា និងត្រា
គង់ សំអុល

លេខ : ១៧៦ ,ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ,ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល
សាឌី តាន់